ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL
ដោះស្រាយវិវាទការងារ

# ព្រឹត្តិបត្រក្រុមប្រឹក្សាអាជ្ញាកណ្តាល

អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងការកាត់សេចក្តី ដោយអាជ្ញាកណ្តាលចងកាតព្វកិច្ច

កក្កដា ២០១១

## ការដោះស្រាយវិវាទការងារដែលគ្របដណ្តប់ដោយអនុស្សារណៈនៃការយោគយល់គ្នា

នៅក្នុងខែកក្កដាឆ្នាំ ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿងវិវាទការងារចំនួន ១៩ ដែលនៅក្នុងនោះ មានសំណុំរឿង ១០ គ្របដណ្តប់ដោយ MoU ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារនៅក្នុងរយៈពេល ១៥ថ្ងៃ ឬក្នុងរយៈពេលពន្យាណាមួយសមស្របដែលមានការយល់ព្រមពីសំណាក់ភាគីវិវាទ ។

ជាសរុប ចាប់ពីខែមករា ដល់ ខែកក្កដា ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលសំណុំរឿងវិវាទការងារចំនួន ៩៧ ដែលនៅក្នុងនោះមានសំណុំរឿង ៤៩ (៥១%) គ្របដណ្តប់ដោយ MoU ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្សះផ្សាសំណុំរឿង ២២ (២៣%) (ទាំងនៅមុនក្នុងពេល និងក្រោយពេលសវនាការ) សំណុំរឿង ៦០ (៦២%) បានដោះស្រាយដោយចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល និងសំណុំរឿង ១៥ (១៥%) គឺកំពុងនៅក្នុងដំណើរការដោះស្រាយនៅឡើយ ។ នៅក្នុងសំណុំរឿងទាំងអស់នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយបានដោយ រហ័ស និងមានតម្លាភាព ។ សេវាកម្មដោយរហ័ស និងមិនលំអៀងនេះបានឆ្លុះបញ្ចាំង ឱ្យឃើញនូវការឆ្លើយតបរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំពោះតម្រូវការរបស់សហគ្រាស និងកម្មករនិយោជិតនៅក្នុងការដោះស្រាយវិវាទការងារ ។

តារាងខាងក្រោមបង្ហាញពីចំនួនសំណុំរឿងសរុបដែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបាន ដោយបែងចែកជាសំណុំរឿងគ្របដណ្តប់ដោយ MoU និងសំណុំរឿងមិនគ្របដណ្តប់ដោយ MoU និងលទ្ធផលជារួមអំពីការដោះស្រាយវិវាទការងារ ។



# ការសង្កេតលើការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា និងសំណុំរឿងដែលកាត់សេចក្តីដោយអាជ្ញាកណ្តាលចងកាតព្វកិច្ច

នៅក្នុងខែកក្កដា ឆ្នាំ ២០១១ មានសំណុំរឿងចំនួន ១០ បានចុះបញ្ជីដែលនៅក្នុងនោះ មានសវនាការលើសំណុំរឿង ៨ កំពុងដំណើរការ នៅក្នុងរយៈពេលធ្វើរបាយការណ៍នេះ ។ មានសំណុំរឿង ២ បានចុះបញ្ជីខែមិថុនា ឆ្នាំ ២០១១ ហើយសវនាការសម្រាប់សំណុំរឿងទាំងនេះ នឹងត្រូវធ្វើឡើងនៅក្នុងខែកក្កដា ។ ភាគីនៅក្នុងសំណុំរឿងទាំងពីរនេះ បានឈានដល់កិច្ចព្រមព្រៀងនៅក្នុងសវនការ ។ ក្នុងចំណោមដំណើរការអាជ្ញាកណ្តាលទាំងអស់ យើងបានសង្កេតឃើញថា:

១. ការវិវត្តន៍ជាវិជ្ជមានទាក់ទងនឹងការអនុវត្តអនុស្សារណៈ

- នៅក្នុងសំណុំរឿង ៨ ភាគីបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងដាច់ដោយឡែក បញ្ជាក់លើការជ្រើសរើសយកអាជ្ញាកណ្តាលជាប់កាតព្វកិច្ចលើវិវាទអំពីសិទ្ធិ ។ ភាគីបានយល់ដឹងអំពីបទប្បញ្ញត្តិរបស់ MoU ជាពិសេសទាក់ទងនឹងអាជ្ញាកណ្តាលជាប់កាតព្វកិច្ចលើវិវាទអំពីសិទ្ធិ ។
- នៅក្នុងសំណុំរឿង ៩ មិនមានសកម្មភាពឧស្សាហកម្ម (កូដកម្ម ឬទ្បុកអៅ) ពាក់ព័ន្ធ ក្នុងអំឡុងពេលនៃការដោះស្រាយវិវាទ ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។
- នៅក្នុងសំណុំរឿង ៨ ភាគីនិយោជករៀបចំបានល្អ ក្នុងការបង្ហាញឯកសារចាំបាច់ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ។
- នៅក្នុងសំណុំរឿង ៥ ភាគីកម្មករនិយោជិតរៀបចំបានល្អ ក្នុងការបង្ហាញឯកសារចាំបាច់ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ។
- នៅក្នុងសំណុំរឿង ៩ ភាគីបានលើកអំណះអំណាងបានល្អនៅក្នុងសវនាការ ។
- នៅក្នុងសំណុំរឿង ៥ ភាគីបង្ហាញឆន្ទៈរបស់ខ្លួនដើម្បីដោះស្រាយវិវាទ តាមរយៈកិច្ចព្រមព្រៀងជាបដិការ ។

២. បញ្ហាប្រឈមនៅក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា

- នៅក្នុងសំណុំរឿង ១ ភាគីមិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដាច់ដោយឡែក បញ្ជាក់លើការជ្រើសរើសយកអាជ្ញាកណ្តាលជាប់កាតព្វកិច្ចលើវិវាទអំពីសិទ្ធិ ។ ភាគីនិយោជកមិនបានយល់ដឹងអំពីបទប្បញ្ញត្តិរបស់ MoU ជាពិសេសទាក់ទងនឹងអាជ្ញាកណ្តាលជាប់កាតព្វកិច្ច លើវិវាទអំពីសិទ្ធិ ។ ភាគីនិយោជកអះអាងថា គាត់មិនបានដឹងអំពីអត្ថន័យរបស់ MoU ទេ ។ ភាគីកម្មករនិយោជិតរៀបចំមិនបានល្អក្នុងការបង្ហាញឯកសារចាំបាច់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល ។
- នៅក្នុងសំណុំរឿង ២ ផ្សេងទៀត កម្មករនិយោជិតមិនបានរៀបចំឱ្យបានល្អ ហើយខកខានបង្ហាញឯកសារចាំបាច់ដល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។
- នៅក្នុងសំណុំរឿង ១ ភាគីនិយោជកមិនមានការងារ ឱ្យកម្មករនិយោជិតធ្វើទេ ។ ភាគីកម្មករនិយោជិត ធ្វើកូដកម្មមួយព្រឹក បន្ទាប់ពីក្រុមប្រឹក្សា-អាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ ដោយសារតែពួកគេមិនពេញចិត្តនឹងសេចក្តីសម្រេចនោះ ។ បន្ទាប់ពីព្រឹកនោះមក ភាគីកម្មករ និយោជិតក៏បានបញ្ឈប់កូដកម្មដែរ ។
- នៅក្នុងសំណុំរឿង ៤ ភាគីមិនមានការសហការគ្នា នៅក្នុងការដោះស្រាយវិវាទ ដោយកិច្ចព្រមព្រៀងទេ ។ ភាគីចង់ឱ្យក្រុមប្រឹក្សាអាជ្ញា-កណ្តាលចេញសេចក្តីបង្គាប់ដើម្បីដោះស្រាយវិវាទរបស់ពួកគេ ។

យើងគោរពភាពឯកជនរបស់លោកអ្នក ហើយនៅក្នុងករណីណាក៏ដោយ យើងនឹងមិនបញ្ចេញព័ត៌មានទំនាក់ទំនងលម្អិតរបស់លោកអ្នក ទៅបុគ្គលណាម្នាក់ រឺអង្គការណាមួយឡើយ ។
ដើម្បីទទួល រឺ ឈប់ទទួល ព្រឹត្តិប័ត្រអេឡិចត្រូនិចនេះ សូមអ៊ីម៉ែលទៅ dvandeth@arbitrationcouncil.org

ផ្ទះលេខ៧២ ផ្លូវ៥៩២ កែង ផ្លូវលេខ៣២៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក
ទូរសព្ទ: ៨៥៥ ២៣ ៨៨១ ៨១៤
ទូរសារ: ៨៥៥ ២៣ ៨៨១ ៩១៨
អ៊ីម៉ែល info@arbitrationcouncil.org
វែបសាយ www.arbitrationcouncil.org